# ព្រះរាជក្រម

នស/រកម/១០១៤/០២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១ មាត្រា៣ មាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា៣០ មាត្រា៣៤ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៩ មាត្រា៥៥ និងមាត្រា៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា ១ មាត្រា ៣ មាត្រា ៤ មាត្រា ៧ មាត្រា ៨ មាត្រា ៩ មាត្រា ១១ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៧ មាត្រា ៣៨ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៩ មាត្រា ៥៥ និងមាត្រា ៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្មដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា១ មាត្រា៣ មាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា៣០ មាត្រា៣៤ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៩ មាត្រា៥៥ និងមាត្រា៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ១.- ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរោងចក្រ និងសិប្បកម្មទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ក្រសួងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា ៣.- ថ្មី**

រោងចក្រ និងសិប្បកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានដូចខាងក្រោម ៖

១-ផ្នែកស្បៀង ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់

២-ផ្នែកវាយនភណ្ឌ សម្លៀកបំពាក់ និងផលិតផលអំពីស្បែក

៣-ផ្នែកផលិតផលក្រដាស

៤-ផ្នែកគីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិច លើកលែងតែឧស្សាហកម្មប្រេងកាត និងឧស្ម័ន

៥-ផ្នែកផលិតផលពីរ៉ែអលោហៈ

៦-ផ្នែកលោហៈមូលដ្ឋាន

៧-ផ្នែកកែច្នៃលោហៈ ម៉ាស៊ីន និងគ្រឿងបរិក្ខារ

៨-ផ្នែកផ្សេងទៀតមានជាអាទិ៍ ផលិតគ្រឿងអលង្ការ រតនភណ្ឌ និងលម្អឧបករណ៍សិល្បៈ កីឡាក្មេងលេង និងសម្ភារៈការិយាល័យ ។

**មាត្រា ៤.- ថ្មី**

ការបង្កើតរោងចក្រដែលមានចែងក្នុងមាត្រា ៣ ថ្មី ត្រូវមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានយោបល់ឯកភាពពីក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ការបង្កើតរោងចក្រផ្ដោតសំខាន់ទៅលើ ៖

- ការរៀបចំទីកន្លែង ឬ/និង ការសាងសង់អគារ សម្រាប់ដំណើរការរោងចក្រ
- ការសាងសង់អគារ សម្រាប់បំពាក់ម៉ាស៊ីនដើម្បីដំណើរការរោងចក្រ
- ការបំពាក់ម៉ាស៊ីនក្នុងអគារ ទីកន្លែង ឬយានយន្ត សម្រាប់ដំណើរការរោងចក្រ
- វត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ ។

**មាត្រា ៧.- ថ្មី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវផ្ដល់លិខិតបញ្ជាក់ផ្សេងៗពាក់ព័ន្ធ នឹងផលិតកម្ម តាមការស្នើសុំរបស់ម្ចាស់រោងចក្រ បើពិនិត្យឃើញថាជាការចាំបាច់ ។

**មាត្រា ៨.- ថ្មី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្មត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកសុំបង្កើតរោងចក្រក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ យ៉ាងយូរនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ក្នុងករណីមិនយល់ព្រមលើពាក្យសុំបង្កើតរោងចក្រ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវពន្យល់ហេតុផលលើការសម្រេចរបស់ខ្លួនឲ្យបានច្បាស់លាស់ ។

**មាត្រា ៩.- ថ្មី**

មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានមុនរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងតិច ។

**មាត្រា ១១.- ថ្មី**

ការពង្រីក ឬការបង្កើតសាខា ឬការផ្លាស់ប្ដូរទីតាំងរោងចក្រត្រូវតែមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ១៣.- ថ្មី**

ក្នុងករណីប្ដូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មីត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធិជាម្ចាស់រោងចក្រថ្មី ។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវឆ្លើយតបទៅម្ចាស់រោងចក្រវិញក្នុងរយៈពេល ០៤ (បួន) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**មាត្រា ១៥._ ថ្មី**

ក្នុងករណីដែលម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាពតាមផ្លូវច្បាប់ អ្នកដែលទទួលសិទ្ធិគ្រប់គ្រងបន្តស្របច្បាប់ ត្រូវធ្វើពាក្យសុំការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ ។

អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត អាចដំណើរការរោងចក្រជាបណ្ដោះអាសន្នបានរហូតមានការទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ១៦._ ថ្មី**

ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ១ (មួយ) ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។

ក្រៅពីករណីប្រធានសក្តិ ការផ្អាកដំណើរការរោងចក្រជាប់ៗគ្នាក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ។ ក្នុងករណីនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញប្រកាសលុបប្រកាសអនុញ្ញាតបង្កើតរោងចក្រ ។

**មាត្រា ១៧._ ថ្មី**

ក្នុងករណីដែលប្រកាសបង្កើតរោងចក្រ ឬ/និងលិខិតអនុញ្ញាតទាំងឡាយ ត្រូវបានបាត់បង់ដោយប្រការណាមួយ ម្ចាស់រោងចក្រត្រូវធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃដែលបានបាត់បង់ ។

**មាត្រា ១៨._ ថ្មី**

រោងចក្រនីមួយៗត្រូវមានឈ្មោះរោងចក្រ ហើយផ្លាកឈ្មោះត្រូវសរសេរជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត ។ ម្ចាស់រោងចក្រត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ការផ្លាស់ប្ដូរឈ្មោះរោងចក្រត្រូវតែមានការយល់ព្រមពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ១៩._ ថ្មី**

ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបាននូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ២០.- ថ្មី**

ម្ចាស់រោងចក្រដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៩ ថ្មី ។

**មាត្រា ២១.- ថ្មី**

ទិន្នន័យ និងរបាយការណ៍ ដែលរោងចក្រផ្តល់ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាការសម្ងាត់វិជ្ជាជីវៈរបស់រោងចក្រ ។ ទិន្នន័យ និងរបាយការណ៍ទាំងនេះមិនត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈឡើយ បើគ្មានការយល់ព្រមពីម្ចាស់រោងចក្រ ។

**មាត្រា ២២.- ថ្មី**

ម្ចាស់រោងចក្រ ដែលស្ថិតនៅក្រោមច្បាប់នេះ មានកាតព្វកិច្ចបង់ប្រាក់កម្រៃសេវាកម្មស្រប តាមការកំណត់នៃប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣.- ថ្មី**

សិប្បកម្មត្រូវបានអនុញ្ញាតឱ្យបង្កើត និងដំណើរការ ដោយម្ចាស់សិប្បកម្មត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដែលខ្លួនបោះទីតាំងក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ក្រោយថ្ងៃដំណើរការ លើកលែងតែប្រភេទសិប្បកម្មដែលមានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្មមុនដំណើរការ ។

បែបបទនៃការបង្កើត និងកិច្ចដំណើរការសិប្បកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ២៤.- ថ្មី**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

ជនណាដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឱ្យមករៀបចំរោងចក្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.– ថ្មី**

ឡចំហាយ ប្រព័ន្ធប្រើប្រាស់ចំហាយឧបករណ៍ ឬធុងដែលប្រើសម្ពាធខ្ពស់ ត្រូវមានការត្រួតពិនិត្យពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម មុននឹងអនុញ្ញាតឲ្យដំណើរការ ។ នៅពេលដំណើរការ ការត្រួតពិនិត្យឧបករណ៍ខាងលើនេះ ត្រូវធ្វើឡើងតាមដំណាក់កាលដែលកំណត់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ៣៤.– ថ្មី**

ក្នុងការអនុវត្តច្បាប់នេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត ឬស្នើទៅរាជរដ្ឋាភិបាលបង្កើតជាអនុក្រឹត្យ ដើម្បីគ្រប់គ្រងរោងចក្រ ។

**មាត្រា ៣៧.– ថ្មី**

មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិចូលទៅក្នុងរោងចក្រ និងសិប្បកម្ម គ្រប់ម៉ោងធ្វើការរបស់រោងចក្រតាមកាលកំណត់ ឬមិនតាមកាលកំណត់ ដើម្បីត្រួតពិនិត្យគុណភាព ស្ថានភាព រោងចក្រ ម៉ាស៊ីន មធ្យោបាយនានា ឬសកម្មភាពផ្សេងៗទៀត ដែលម្ចាស់រោងចក្ររំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើអធិការកិច្ចរោងចក្រដោយ ៖

១-យកផលិតផលក្នុងបរិមាណសមស្រប ដើម្បីធ្វើការវិភាគអំពីគុណភាព រួមជាមួយ នឹងឯកសារពាក់ព័ន្ធ ។

២-ធ្វើការស្រាវជ្រាវ បញ្ឈប់ ឬឃាត់ទុកនូវផលិតផល សម្ភារៈ វត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានា ដែលអាចបណ្តាលឲ្យមានអន្តរាយដល់មនុស្ស ឬដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬទីជិតខាងរោងចក្របាន ។

៣-សាកសួរ ឬកោះអញ្ជើញម្ចាស់រោងចក្រ អ្នកគ្រប់គ្រងរោងចក្រ និយោជិត ឬកម្មករក្នុងរោងចក្រ មកបំភ្លឺព័ត៌មាន ឬសុំឲ្យផ្តល់ព័ត៌មាន និងឯកសារ ។

**មាត្រា ៣៨.– ថ្មី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិផ្អាកសកម្មភាពរោងចក្រទាំងឡាយណាដែលបានបង្កើតដោយគ្មានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្មជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីតម្រូវឲ្យម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវ និងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញប្រកាសអនុញ្ញាតឲ្យបង្កើតរោងចក្រ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនត្រឹមត្រូវ ឬមិនទាន់តាមកាលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ជាផ្អាកដំណើរការផលិតកម្ម ឬប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈនៅពីមុខរោងចក្រ ឬចុះផ្សាយតាមសារព័ត៌មាន ។

**មាត្រា ៣៩.‒ ថ្មី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិចេញបញ្ជាឲ្យម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រផ្អាកដំណើរការផលិតកម្មទាំងមូល ឬតាមផ្នែកនៃរោងចក្រជាបណ្តោះអាសន្នក្នុងរយៈពេលមួយមានកំណត់ ដើម្បីឲ្យម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រធ្វើការកែតម្រូវ ឬកែលម្អឲ្យបានប្រសើរឡើងវិញក្នុងករណី ៖

-មានកំហុសធ្ងន់ធ្ងរផ្នែកបច្ចេកទេស ដូចមានចែងក្នុងមាត្រា ២៤ ថ្មី

-កិច្ចដំណើរការផលិតកម្ម ខុសពីការអនុញ្ញាតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-កិច្ចដំណើរការផលិតកម្ម ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយដល់ទ្រព្យសម្បត្តិនៅក្នុងរោងចក្រ ឬក្រៅរោងចក្រ

-ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ មានចេតនាមិនគោរពតាមលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

ប្រសិនបើការកែតម្រូវធ្វើឡើងបានត្រឹមត្រូវនិងទាន់ពេលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចេញបញ្ជាអនុញ្ញាតឲ្យរោងចក្របន្តដំណើរការផលិតកម្មឡើងវិញ ។

ប្រសិនបើការកែតម្រូវមិនបានអនុវត្ត ឬអនុវត្តមិនទាន់កាលកំណត់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានអំណាចចេញប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ។

បញ្ជាផ្អាកដំណើរការផលិតកម្ម ឬប្រកាសបិទទ្វាររោងចក្រជាស្ថាពរ ត្រូវបិទផ្សាយជាសាធារណៈនៅពីមុខរោងចក្រ ឬចុះផ្សាយតាមសារព័ត៌មាន ។

**មាត្រា ៤០.‒ ថ្មី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិបញ្ជូនលិខិតបញ្ជាទៅកាន់គេហដ្ឋាន ឬរោងចក្ររបស់ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ដែលត្រូវទទួលលិខិតបញ្ជានេះដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋ ដោយមានចុះហត្ថលេខាបានទទួល ។

ក្នុងករណីដែលម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ បដិសេធមិនព្រមទទួលលិខិតបញ្ជារបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិអញ្ជើញមេឃុំ ឬស្នងការនគរបាលឲ្យចូលរួមជាមួយខ្លួនដើម្បីធ្វើជាសាក្សី ។ បើម្ចាស់រោងចក្រ ឬអ្នកគ្រប់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

គ្រងរោងចក្រមិនស្ថិតក្នុងគេហដ្ឋាន ឬក្នុងរោងចក្រទេនោះ លិខិតបញ្ជាអាចត្រូវបានប្រគល់ទៅឲ្យជនណាម្នាក់ ដែលមានការពាក់ព័ន្ធតាមផ្លូវច្បាប់ជាមួយនឹងម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ។

ប្រសិនបើលិខិតបញ្ជានៅតែគ្មានអ្នកទទួលជំនួស ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបិទលិខិតបញ្ជានោះនៅច្រកចូល ឬមាត់ទ្វាររោងចក្រ ឬនៅគេហដ្ឋានរបស់ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រនោះ ដោយមានវត្តមានរបស់អាជ្ញាធរ ឬភ្នាក់ងារនគរបាលជាសាក្សី ។

ក្រោយពីប្រតិបត្តិដូចបានចែងក្នុងវាក្យខណ្ឌខាងលើ លិខិតបញ្ជាត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ។

**មាត្រា ៤១.- ថ្មី**

ក្នុងករណីដែលមានឧប្បត្តិហេតុ ឬគ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឲ្យរោងចក្រត្រូវផ្អាកដំណើរការទាំងស្រុងលើសពី ៧ (ប្រាំពីរ)ថ្ងៃ ម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុនោះ ។

ពេលដែលមានឧប្បត្តិហេតុ ឬគ្រោះថ្នាក់កើតឡើងដូចខាងលើ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធ្វើអធិការកិច្ចរោងចក្រ ហើយអនុវត្តតាមមាត្រា ៣៧ ថ្មី ឬមាត្រា ៣៩ ថ្មី វាក្យខណ្ឌទី ១ ប្រសិនបើចាំបាច់ ។

**មាត្រា ៤២.- ថ្មី**

ក្នុងការចុះធ្វើអធិការកិច្ច មន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន និងលិខិតបញ្ជាបេសកកម្មជូនទៅម្ចាស់រោងចក្រ ឬជនដែលខ្លួនត្រូវទំនាក់ទំនង ។

ការធ្វើអធិការកិច្ចរោងចក្រ ត្រូវមានកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

**មាត្រា ៤៣.- ថ្មី**

ម្ចាស់សិប្បកម្មណា ដែលពុំបានធ្វើការជូនដំណឹងជាលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំងដូចកំណត់ក្នុងមាត្រា ២៣ ថ្មី វាក្យខណ្ឌទី ១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០ ០០០ រៀល (ប្រាំរយពាន់រៀល) ទៅ ២ ៥០០ ០០០ រៀល (ពីរលានប្រាំរយពាន់រៀល) ។

ជនណាបង្កើតប្រភេទសិប្បកម្ម ដែលមានចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចក្នុងមាត្រា ២៣ ថ្មី ដោយគ្មានការអនុញ្ញាត ឬល្មើសនឹងមាត្រា ២៣ ថ្មី ឬបទប្បញ្ញត្តិដទៃ

ទៀតពាក់ព័ន្ធនឹងមាត្រា ២៣ ថ្មី វាក្យខណ្ឌទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ រៀល (មួយលានរៀល) ទៅ ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ។

**មាត្រា ៤៥.– ថ្មី**

ម្ចាស់រោងចក្រណាដែលប្រព្រឹត្តល្មើស នឹងមាត្រា ២៤ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ទៅ ២៥ ០០០ ០០០ រៀល (ម្ភៃប្រាំលានរៀល) ។

ប្រសិនបើមានគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រព្រឹត្តល្មើស នឹងមាត្រាខាងលើ ម្ចាស់រោងចក្រត្រូវទទួលសងការខូចខាតទាំងអស់ដល់ជនរងគ្រោះ ។ ក្នុងករណីនេះ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។

**មាត្រា ៤៦.– ថ្មី**

ម្ចាស់រោងចក្រណា ដែលប្រព្រឹត្តិល្មើសនឹងមាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ និងមាត្រា ៣០ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ រៀល (ពីរលានរៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) ។

ក្នុងករណីបទល្មើសនេះបង្កឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយដល់ទ្រព្យសម្បត្តិក្នុង ឬក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមព្យសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៤៩.– ថ្មី**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤ ថ្មី មាត្រា ៩ ថ្មី និងមាត្រា ២០ ថ្មី នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ រៀល (ដប់លានរៀល) ទៅ ៥០ ០០០ ០០០ រៀល (ហាសិបលានរៀល) ។

ក្នុងករណីបទល្មើសនេះបណ្តាលឲ្យមានគ្រោះថ្នាក់ដល់មនុស្ស ឬអន្តរាយទ្រព្យសម្បត្តិក្នុង ឬក្រៅរោងចក្រ មន្ត្រីមានសមត្ថកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីសម្រេចអំពីសំណងអន្តរាយទៅតាមព្យសនកម្ម និងផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៥៥.– ថ្មី**

ទោសទណ្ឌទាំងឡាយណាដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០ ០០០ រៀល (ប្រាំរយពាន់រៀល) ទៅ ១០ ០០០ ០០០ រៀល (ដប់លានរៀល) មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសិទ្ធិពិន័យអន្តរការណ៍ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីរឹងរូស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ៥៦.- ថ្មី**

ក្រោយពីច្បាប់នេះចូលជាធរមាន រោងចក្រ សិប្បកម្មទាំងអស់ដែលបានបង្កើតរួចហើយ និងមិនទាន់មានប្រកាសបង្កើតរោងចក្រ ឬលិខិតអនុញ្ញាត ឬមិនទាន់បានចុះបញ្ជីត្រូវមកបំពេញសំណុំបែបបទឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដែលសិប្បកម្មបោះទីតាំងក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ ។ ក្នុងករណីចាំបាច់ រយៈពេលនេះអាចបន្តបាន ៣ (បី) ខែបន្ថែម ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤

នស.រកម.១០១៤.០៣០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខ: ១៣៦៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**